ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៤៧០ សហវ.ប្រក

# ប្រកាស
## ស្តីពី
## វិធាននិងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ នៅអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០១០ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ
- បានឃើញ ព្រះរាជក្រមលេខ ១១/នស/៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ១៩៩៥
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងធានាតម្លាភាព សុចរិតភាព យុត្តិធម៌ សុក្រឹតភាព និងភាពទាន់ពេល នៃការដោះស្រាយបណ្តឹងតវ៉ាពន្ធដារ របស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីវិធាននិងនីតិវិធី នៃការដាក់ពាក្យបណ្តឹងតវ៉ា និងការដោះស្រាយបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក នៅក្នុងកម្រិតអគ្គនាយកដ្ឋានពន្ធដារ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្ត ចំពោះបណ្តឹងតវ៉ាខាងរដ្ឋបាលរបស់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ចំពោះសេចក្តីសម្រេច ឬវិធានការរបស់អគ្គនាយកដ្ឋានពន្ធដារ ឬអង្គភាពក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ពាក់ព័ន្ធការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ ការទារបំណុលពន្ធ សេចក្តីសម្រេច និងវិធានការពន្ធដារផ្សេងទៀត។

**ប្រការ៤.-**

ក្នុងក្របខ័ណ្ឌនៃប្រកាសនេះ និយមន័យនៃបច្ចេកសព្ទ ត្រូវបានកំណត់ ដូចខាងក្រោម÷

- "**ការកំណត់ពន្ធ**" សំដៅដល់ការកំណត់ចំនួនប្រាក់ពន្ធ ដោយអនុលោមតាមមាត្រា១១៦ នៃច្បាប់ស្តីពីសារពើពន្ធ។
- "**ការកំណត់ពន្ធឡើងវិញ**" សំដៅដល់ការកំណត់ពន្ធដោយអនុលោមតាមមាត្រា១១៧ នៃច្បាប់ស្តីពីសារពើពន្ធ។
- "**អង្គភាពពន្ធដារ**" សំដៅដល់គ្រប់នាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ ក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ។
- "**អង្គភាពកំណត់ពន្ធ**" សំដៅដល់នាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ ក្រោមឱវាទអគ្គនាយកដ្ឋានពន្ធដារ ដែលមានភារកិច្ចកំណត់ពន្ធ ឬកំណត់ពន្ធឡើងវិញ។
- "**អង្គហេតុ**" សំដៅដល់ដំណើររឿងដែលកើតឡើងពាក់ព័ន្ធការតវ៉ាអំពីការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ និងការប្រមូលពន្ធ ព្រមទាំងសេចក្តីសម្រេច និងវិធានការពន្ធដារផ្សេងទៀត។
- "**អង្កេតដើមហេតុ**" សំដៅដល់ការស្រាវជ្រាវ និងការពិនិត្យឡើងវិញរបស់អង្គភាពពន្ធដារទទួលបន្ទុកដោះស្រាយបណ្តឹងតវ៉ា ដែលពាក់ព័ន្ធនឹងការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ និងការប្រមូលពន្ធ ព្រមទាំងសេចក្តីសម្រេច និងវិធានការពន្ធដារផ្សេងទៀត។
- "**អ្នកតវ៉ា**" សំដៅដល់អ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុក ដែលធ្វើការតវ៉ាចំពោះសេចក្តីសម្រេច ឬវិធានការពាក់ព័ន្ធពន្ធដារនានា ដែលដាក់ឱ្យអនុវត្តដោយអគ្គនាយកដ្ឋានពន្ធដារ ឬអង្គភាពកំណត់ពន្ធ។

## ជំពូកទី២

## នីតិវិធីដាក់ពាក្យបណ្តឹងតវ៉ា

**ប្រការ៥.-**

អ្នកតវ៉ា ដែលមិនពេញចិត្តនឹងការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ ការទារបំណុលពន្ធ សេចក្តីសម្រេច ឬវិធានការផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ មានសិទ្ធិដាក់ពាក្យបណ្តឹងតវ៉ា ទៅអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ

ក្នុងរយៈពេល ៣០ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទ នៃការទទួលលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេច ឬវិធានការផ្សេងៗរបស់អគ្គនាយកដ្ឋានពន្ធដារ។

សិទ្ធិតវ៉ានេះ ត្រូវកម្រិតព្រំដែន ត្រឹមដើមហេតុ ឬព័ត៌មានផ្សេងទៀត ដែលមាននៅក្នុងការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ សេចក្តីសម្រេច ឬវិធានការផ្សេងៗ ឬនីតិវិធីប្រមូលពន្ធរបស់រដ្ឋបាលពន្ធដារប៉ុណ្ណោះ។

អ្នកតវ៉ា មិនអាចដាក់ពាក្យបណ្តឹងតវ៉ាជាសមូហភាពបានទេ លើកលែងតែអ្នកតវ៉ានោះ ត្រូវបានកំណត់ពន្ធជារួម។

ក្នុងករណីដែលអ្នកតវ៉ាបានដាក់ពាក្យបណ្តឹងតវ៉ា ហួសរយៈពេលកំណត់ ដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អាចចេញសេចក្តីសម្រេចបដិសេធពាក្យបណ្តឹងតវ៉ា ដោយត្រូវបញ្ជាក់ហេតុផលឱ្យបានច្បាស់លាស់។

**ប្រការ៦.-**

ពាក្យបណ្តឹងតវ៉ា ត្រូវចុះហត្ថលេខាដោយអ្នកតវ៉ាផ្ទាល់ ឬតំណាងស្របច្បាប់។ អ្នកតវ៉ាអាចចាត់តំណាងស្របច្បាប់ ដែលមានសិទ្ធិសម្រេច ចូលរួមក្នុងនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ាជំនួស ដោយមានភ្ជាប់មកជាមួយពាក្យបណ្តឹងតវ៉ា និងលិខិតផ្ទេរសិទ្ធិដែលមានចុះហត្ថលេខារបស់សាមីអ្នកតវ៉ា។

ពាក្យបណ្តឹងតវ៉ា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយត្រូវមានខ្លឹមសារនិងព័ត៌មាន ដូចខាងក្រោម÷

- កាលបរិច្ឆេទនៃបណ្តឹងតវ៉ា
- អត្តសញ្ញាណរបស់អ្នកជាប់ពន្ធ ជាអាទិ៍ VAT TIN និង/ឬ PIN ប្រសិនបើមាន
- អាសយដ្ឋាន លេខទូរសព្ទ និង/ឬ សារអេឡិចត្រូនិក របស់អ្នកតវ៉ា ឬតំណាងស្របច្បាប់របស់អ្នកតវ៉ា
- ការយោងលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ ការប្រមូលពន្ធ ឬសេចក្តីសម្រេចផ្សេងទៀតពាក់ព័ន្ធវិធានការពន្ធដារ ដែលជាកម្មវត្ថុនៃបណ្តឹងតវ៉ា
- អង្គហេតុ ឬវិធានការដាក់ចេញដោយអគ្គនាយកដ្ឋានពន្ធដារ ឬអង្គភាពកំណត់ពន្ធ ដែលជាកម្មវត្ថុនៃបណ្តឹងតវ៉ា
- សំអាងហេតុ និងមូលដ្ឋានគតិយុត្ត នៃបណ្តឹងតវ៉ា ដែលសាមីអ្នកតវ៉ាលើកជាសំអាង ក្នុងការតវ៉ាទៅនឹងវិធានការពាក់ព័ន្ធពន្ធដារ ដែលសម្រេចដោយអគ្គនាយកដ្ឋានពន្ធដារ ឬអង្គភាពកំណត់ពន្ធ
- ព័ត៌មានចាំបាច់ផ្សេងទៀតពាក់ព័ន្ធបណ្តឹងតវ៉ា។

គំរូនៃពាក្យបណ្តឹងតវ៉ា ត្រូវបានកំណត់ជាឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ៧.-**

ពាក្យបណ្តឹងតវ៉ា ត្រូវភ្ជាប់មកជាមួយ នូវភស្តុតាង ជាអាទិ៍ដូចខាងក្រោម÷

- លិខិតជូនដំណឹងស្តីពីការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ ការទារបំណុលពន្ធ ឬសេចក្តីសម្រេចផ្សេងទៀតពាក់ព័ន្ធវិធានការពន្ធដារ ដែលជាកម្មវត្ថុនៃបណ្តឹងតវ៉ា
- ឯកសារដែលបញ្ជាក់ពីការទូទាត់ប្រាក់ពន្ធ ជាអាទិ៍ ប្រកាសឥណទានធនាគារ និងបង្កាន់ដៃឬលិខិតបញ្ជាក់ការបង់ពន្ធក្នុងករណីដែលបានបង់ពន្ធរួច
- ភស្តុតាងផ្សេងទៀត ពាក់ព័ន្ធអង្គហេតុឬសំអាងហេតុ នៃបណ្តឹងតវ៉ារបស់អ្នកតវ៉ា ជាអាទិ៍ ទិនានុប្បវត្តិ វិក្កយបត្រ កិច្ចសន្យា លិខិតយុត្តិការឬឯកសារផ្សេងៗ។

**ប្រការ៨.-**

ក្នុងករណី លក្ខខណ្ឌនៃការដាក់ពាក្យបណ្ដឹងតវ៉ា ដូចមានកំណត់ក្នុងប្រការ៦ និងប្រការ៧ ខាងលើ ពុំត្រូវបានបំពេញគ្រប់គ្រាន់ដោយអ្នកតវ៉ា អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អាចចេញសេចក្ដីសម្រេចបដិសេធពាក្យបណ្ដឹងតវ៉ា ដោយត្រូវបញ្ជាក់ហេតុផលឱ្យបានច្បាស់លាស់។

## ជំពូកទី៣
## នីតិវិធីដោះស្រាយបណ្ដឹងតវ៉ា

**ប្រការ៩.-**

នីតិវិធីនៃការដោះស្រាយបណ្ដឹងតវ៉ា មានដំណាក់កាល ដូចខាងក្រោម÷

១- ចុះបញ្ជីនិងគ្រប់គ្រងបណ្ដឹងតវ៉ា

២- ពិនិត្យរបាយការណ៍បំភ្លឺដែលធ្វើឡើងដោយអង្គភាពកំណត់ពន្ធ និងអង្គភាពប្រមូលពន្ធ

៣- អង្កេតដើមហេតុនៃបណ្ដឹងតវ៉ា

៤- សេចក្ដីសម្រេចលើបណ្ដឹងតវ៉ា

៥- ជូនដំណឹងអំពីសេចក្ដីសម្រេចដោះស្រាយបណ្ដឹងតវ៉ា។

**ប្រការ១០.-**

ក្នុងដំណាក់កាលចុះបញ្ជីនិងគ្រប់គ្រងបណ្ដឹងតវ៉ា ការិយាល័យវិវាទ នៃនាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ មានភារកិច្ចកត់ត្រាចុះបញ្ជី គ្រប់គ្រង និងបែងចែកបណ្ដឹងតវ៉ារបស់អ្នកជាប់ពន្ធតាមប្រភេទនីមួយៗ បន្ទាប់ពីបានត្រួតពិនិត្យសង្ខេបខ្លឹមសារ និងកំណត់កម្មវត្ថុនៃបណ្ដឹងតវ៉ា ហើយត្រូវផ្ញើជូនទៅអង្គភាពកំណត់ពន្ធ ឬអង្គភាពប្រមូលពន្ធ ដើម្បីស្នើសុំរបាយការណ៍បំភ្លឺពាក់ព័ន្ធនឹងបណ្ដឹងតវ៉ា។

**ប្រការ១១.-**

បន្ទាប់ពីទទួលបានសំណើសុំការបំភ្លឺលើបណ្ដឹងតវ៉ា អង្គភាពកំណត់ពន្ធ និង/ឬ អង្គភាពប្រមូលពន្ធ ត្រូវរៀបចំរបាយការណ៍បំភ្លឺលើបណ្ដឹងតវ៉ា ដូចខាងក្រោម÷

- អង្គភាពកំណត់ពន្ធ ត្រូវបញ្ជាក់អំពីអនុលោមភាពនៃនីតិវិធីនិងមូលដ្ឋាននៃការកំណត់ពន្ធ ឬការកំណត់ពន្ធឡើងវិញ សេចក្ដីសម្រេច និងវិធានការពន្ធដារផ្សេងទៀតរបស់សាមីអង្គភាព។
- អង្គភាពប្រមូលពន្ធ ត្រូវបញ្ជាក់អំពីអនុលោមភាពនៃនីតិវិធីប្រមូលពន្ធ ការទារបំណុលពន្ធ ការពិន័យ សេចក្ដីសម្រេច និងវិធានការពន្ធដារផ្សេងទៀតរបស់សាមីអង្គភាព។

របាយការណ៍បំភ្លឺនេះ ត្រូវផ្ញើជូនទៅនាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ យ៉ាងយូរ ក្នុងរយៈពេល ៧ ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងស្ដីពីការស្នើសុំរបាយការណ៍បំភ្លឺពីនាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ ដោយពុំអនុញ្ញាតឱ្យអង្គភាពកំណត់ពន្ធ និង/ឬអង្គភាពប្រមូលពន្ធ ធ្វើការកែតម្រូវនូវតួលេខ ដែលជាមូលដ្ឋាននៃការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ ឬបំណុលពន្ធឡើយ។

**ប្រការ១២.-**

បន្ទាប់ពីទទួលបានពាក្យបណ្ដឹងតវ៉ា និង/ឬរបាយការណ៍បំភ្លឺ មន្ត្រីការិយាល័យវិវាទនៃនាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ ដែលទទួលបន្ទុកអង្កេតដើមហេតុបណ្ដឹងតវ៉ា ត្រូវដំណើរការអង្កេតដើមហេតុ ដូចខាងក្រោម÷

- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងដើមហេតុនៃបណ្តឹងតវ៉ា ពាក់ព័ន្ធនឹងការកំណត់ពន្ធ ការកំណត់ពន្ធឡើងវិញ និងការប្រមូលពន្ធ របស់អង្គភាពកំណត់ពន្ធ និង/ឬអង្គភាពប្រមូលពន្ធ ព្រមទាំងបន្ទុកភស្តុតាង ឬសេចក្តីបរិយាយក្នុងពាក្យបណ្តឹងតវ៉ា
- អញ្ជើញសវនករ ឬមន្ត្រីទទួលបន្ទុកប្រមូលពន្ធ ឬមន្ត្រីទទួលបន្ទុកកំណត់ពន្ធ និង/ឬអ្នកតវ៉ា មកបំភ្លឺ ឬតម្រូវឱ្យផ្តល់ភស្តុតាងបន្ថែម
- ក្នុងករណីចាំបាច់ត្រូវចុះពិនិត្យអង្កេតដល់ទីកន្លែង ឬ ប្រើប្រាស់សិទ្ធិទាមទារព័ត៌មានចំពោះតតិយជន ស្របតាមមាត្រា៩២ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ១៣.-**

បន្ទាប់ពីបញ្ចប់ដំណាក់កាលអង្កេតដើមហេតុលើពាក្យបណ្តឹងតវ៉ា ដូចមានចែងក្នុងប្រការ១២ នៃប្រកាសនេះ នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ ត្រូវធ្វើការសន្និដ្ឋានដោយមានសំអាងហេតុ ផ្អែកលើអង្គហេតុនិងអង្គច្បាប់ពាក់ព័ន្ធ ដើម្បីលើកសំណើសុំការពិនិត្យនិងសម្រេចពីអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ។

អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវចេញសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា ក្នុងរយៈពេល ៦០ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទទទួលពាក្យបណ្តឹងតវ៉ា។

សេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា ត្រូវមានបញ្ជាក់អំពីអង្គហេតុ អង្គច្បាប់ និងសំអាងហេតុ ដែលជាមូលដ្ឋាននៃសេចក្តីសម្រេចច្បាស់លាស់។

**ប្រការ១៤.-**

លិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ាត្រូវផ្ញើជូនអ្នកតវ៉ា និងត្រូវចម្លងជូនអង្គភាពកំណត់ពន្ធ និង/ឬអង្គភាពប្រមូលពន្ធពាក់ព័ន្ធ ដើម្បីរៀបចំបញ្ចូលក្នុងសំណុំឯកសារសហគ្រាស និងកត់ត្រាក្នុងព្រឹត្តបត្រព័ត៌មានអនុរក្ស។

អង្គភាពប្រមូលពន្ធ ត្រូវរាយការណ៍មកនាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ អំពីការទូទាត់បំណុលពន្ធ ដោយភ្ជាប់ជាមួយនូវប្រកាសឥណទានធនាគារ និងបង្កាន់ដៃឬលិខិតបញ្ជាក់ការបង់ប្រាក់ពន្ធ ដែលពាក់ព័ន្ធនឹងសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា យ៉ាងយូរ ០៥ ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃការទូទាត់បំណុលពន្ធរួច។

**ប្រការ១៥.-**

អ្នកតវ៉ា ដែលមិនពេញចិត្ត នឹងសេចក្តីសម្រេចដោះស្រាយ ឬសេចក្តីសម្រេចបដិសេធបណ្តឹងតវ៉ា របស់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អាចដាក់ពាក្យតវ៉ាទៅគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ក្នុងរយៈពេល ៣០ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទនៃការទទួលបានលិខិតជូនដំណឹងស្តីពីសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា ឬសេចក្តីសម្រេចបដិសេធ របស់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ដោយចម្លងជូនអគ្គនាយកដ្ឋានពន្ធដារមួយច្បាប់។

ហួសរយៈពេលកំណត់ ដូចមានចែងក្នុងកថាខណ្ឌ១ នៃប្រការនេះ សេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ា ឬសេចក្តីសម្រេចបដិសេធ របស់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ ត្រូវមានអានុភាពអនុវត្ត និងពុំអាចធ្វើជាកម្មវត្ថុនៃការដាក់ពាក្យបណ្តឹងតវ៉ាទៅគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធឡើយ។

ការទទួលដោះស្រាយបណ្តឹងតវ៉ា ដោយគណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធ ត្រូវមានអានុភាពផ្អាកការអនុវត្តសេចក្តីសម្រេចដោះស្រាយបណ្តឹងតវ៉ារបស់អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**ប្រការ១៦.-**

ប្រកាសលេខ ០៥០ ប្រក.សហវ.ពដ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ១៩៩៦ ស្តីពីនីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ា និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៥

**បណ្ឌិត. អ៊ុន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ១៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ១៤៧០ សហវ.ប្រក
ចុះថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ២០១៥

<u>**គំរូទី១.** ពាក្យបណ្តឹងតវ៉ា របស់អ្នកជាប់ពន្ធជារូបវន្តបុគ្គល</u>

## ពាក្យបណ្តឹងតវ៉ារបស់អ្នកជាប់ពន្ធ

ឈ្មោះ÷
អត្តសញ្ញាណ÷ (លេខអត្តសញ្ញាណបណ្ណ ឬលិខិតឆ្លងដែន)
អាសយដ្ឋាន÷
លេខទូរស័ព្ទ÷
សារអេឡិចត្រូនិច÷

....., ថ្ងៃទី..... ខែ..... ឆ្នាំ.....

**សូមគោរពជូន**
**ឯកឧត្តម (គោរមងារ) អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ**

**កម្មវត្ថុ** ÷ ..... ។
**យោង** ÷ - (សេចក្តីសម្រេច ឬវិធានការណ៍ និងកាលបរិច្ឆេទ ដែលជាកម្មវត្ថុនៃបណ្តឹង)
- (លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ បើសិនជាមាន)
- (ឯកសារ ឬភ័ស្តុតាង)។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូនឯកឧត្តម (គោរមងារ) អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ មេត្តាជ្រាបថា ផ្អែកតាម (សេចក្តីសម្រេច ឬវិធានការណ៍ ដោយមានបញ្ជាក់កាលបរិច្ឆេទ ដែលអ្នកតវ៉ាមិនពេញចិត្ត) ខ្ញុំបាទ/នាងខ្ញុំ យល់ឃើញ ដូចខាងក្រោម÷

ក. អង្គហេតុ

.....

ខ. មូលដ្ឋាន និងសំអាងហេតុ

.....

គ. សន្និដ្ឋាន

.....

អាស្រ័យហេតុនេះ ខ្ញុំសូមឯកឧត្តម អគ្គនាយកមេត្តាពិនិត្យនិងដោះស្រាយលើពាក្យបណ្តឹងរបស់ខ្ញុំបាទ/នាងខ្ញុំ ខាងលើ ដោយក្តីអនុគ្រោះ។

សូមឯកឧត្តម (គោរមងារ) អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារទទួលនូវការគោរព អំពីខ្ញុំបាទ/នាងខ្ញុំ

ឈ្មោះអ្នកតវ៉ា ឬតំណាងស្របច្បាប់
ហត្ថលេខា ឬ ស្នាមមេដៃ

**គំរូទី២. ពាក្យបណ្ដឹងតវ៉ា របស់អ្នកជាប់ពន្ធជានីតិបុគ្គល**

# ពាក្យបណ្ដឹងតវ៉ារបស់អ្នកជាប់ពន្ធ

នាមករណ៍ក្រុមហ៊ុន÷

អត្តសញ្ញាណ÷ (VAT IN/PIN/...)

អាសយដ្ឋានទីស្នាក់ការ÷

លេខទូរស័ព្ទ÷

សារអេឡិចត្រូនិច÷ ....., ថ្ងៃទី..... ខែ..... ឆ្នាំ.....

**សូមគោរពជូន**

**ឯកឧត្តម (គោរមងារ) អគ្គនាយកនៃអគ្គនាយដ្ឋានពន្ធដារ**

**កម្មវត្ថុ** ÷ ..... ។

**យោង** ÷ - (សេចក្ដីសម្រេច ឬវិធានការណ៍ និងកាលបរិច្ឆេទ ដែលជាកម្មវត្ថុនៃបណ្ដឹង)

- (លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ បើសិនជាមាន)
- (ឯកសារ ឬភ័ស្តុតាង)។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូនឯកឧត្តម (គោរមងារ) អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ មេត្តាជ្រាបថា ផ្អែកតាម (សេចក្ដីសម្រេច ឬវិធានការណ៍ ដោយមានបញ្ជាក់កាលបរិច្ឆេទ ដែលអ្នកតវ៉ាមិនពេញចិត្ត) ខ្ញុំបាទ/នាងខ្ញុំ យល់ឃើញ ដូចខាងក្រោម÷

ក. អង្គហេតុ

.....

ខ. មូលដ្ឋាន និងសំអាងហេតុ

.....

គ. សន្និដ្ឋាន

.....

អាស្រ័យហេតុនេះ ខ្ញុំសូមឯកឧត្តម អគ្គនាយកមេត្តាពិនិត្យនិងដោះស្រាយលើពាក្យបណ្ដឹងរបស់ខ្ញុំបាទ/នាងខ្ញុំ ខាងលើ ដោយក្ដីអនុគ្រោះ។

សូមឯកឧត្តម (គោរមងារ) អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារទទួលនូវការគោរព អំពីខ្ញុំបាទ/នាងខ្ញុំ

តំណាងស្របច្បាប់របស់ក្រុមហ៊ុន

ហត្ថលេខា

(ត្រារបស់ក្រុមហ៊ុន)